# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## ពិតថេរដីកាព្រះគុណម្ចាស់

ព្រះចៅអធិការវត្ត និង ព្រះសង្ឃទាំងអស់ដែលគង់នៅសហគមន៍វត្តខ្មែរទាំងអស់នៅសហរដ្ឋអាមេរិច

កម្មវត្ថុ: ខ្ញុំព្រះកុរណាជាព្រះចៅអធិការវត្តសិលាចារបន្ទាយស្រី សូមពិតថេរដីកា និង ស្នើរសុំអោយព្រះ ចៅអធិការវត្ត ព្រមទាំងព្រះតេជគុណទាំងអស់ដែលនៅគង់សហគមន៍វត្តខ្មែរទាំងអស់ នៅសហរដ្ឋអាមេរិចជួយគាំទ្រថែរក្សា និង ទទួលការស្នាក់នៅចំពោះកូនសិស្សសិល្បៈទាំងអស់ដែលជាសិស្សសាលាសិល្បៈបណ្តុះបណ្តាលវិជ្ជាជីវៈសម្តេចព្រះរាមបុប្ផាទេវីឈូកសបន្ទាយស្រី ដោយសិស្សទាំងអស់នេះ និងធ្វើដំណើរទៅសហរដ្ឋអាមេរិចចាប់តាំងពីថ្ងៃ ទី១៤ ខែកញ្ញា ឆ្នាំ ២០១៣ រហូតដល់ ថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៣។

តបតាមកម្មវត្ថុដូចបានពិតថេរដីកា សូមព្រះតេជព្រះគុណជួយគាំទ្រ ថែរក្សា និង ទទួលការស្នាក់នៅ ដល់កូនសិស្សទាំងអស់ផង ដោយកូនសិស្សទាំងអស់នោះគឺជាកូនសិស្សដែលបានកើតនៅលើទឹកដីអង្គរ ហើយជាអ្នកដែលគោរពព្រះពុទ្ធសាសនា ព្រមទាំងធ្លាប់បានចូលរួមបំបួស (សមាធិកម្មដ្ឋាន) ចំនួន៧ថ្ងៃនៅវត្តសិលាចារបន្ទាយស្រី ដែលស្ថិតនៅភូមិបន្ទាយស្រី ឃុំខ្នារសណ្តាយ ស្រុកបន្ទាយស្រី ខេត្តសៀមរាប កត្តាទាំងនេះហើយដែលបណ្តាលចិត្តរបស់ពួកគេកាន់តែគោរពស្រលាញ់ពុទ្ធសាសនាខ្លាំងឡើងៗ កូនសិស្សទាំងនោះតែងតែ មកសុំសីលរៀងរាល់ថ្ងៃសីលពេញបូណ៌មីចំណែកឯ នៅសាលាសិល្បៈវិញពួកគេតែងតែធ្វើសមាធិចំនួន៣០នាទីសិន ដើម្បីធ្វើអោយមានភាពស្ងប់ស្ងាត់ក្នុងចិត្តមុន និង ហាត់សិល្បៈ។

អាស្រ័យហេតុដូចបានពិតថេរដីកាខាងលើសូមព្រះតេជព្រះគុណទទួលការគោរពរាប់អាន និង នឹករលឹកពីចំងាយពីខ្ញុំព្រះកុរណា។

បន្ទាយស្រី ថ្ងៃ ទី០៧ ខែ កក្កដា ឆ្នាំ ២០១៣

ចៅអធិការវត្ត

ព្រះនាម ពេជ្រ ព្រហ្ម

ស៊ុរ ស៊ុន